# សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង

សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០៧ មិនា ២០១៤

- **សូមគោរព លោក សៀក គុណារត្ន័ តំណាងសមាគម (JATA)!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ទៅលើគម្រោងពង្រឹងសមត្ថភាពការធ្វើរោគវិនិច្ឆ័យជំងឺរបេង។

សមាគមកំចាត់រោគរបេងជប៉ុន បាននិងកំពុងបន្តសកម្មភាពផ្តល់ជំនួយក្នុងការកំចាត់ជំងឺរបេងនៅកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយក៏ធ្លាប់សហការទៅលើគម្រោងវិធានការទប់ស្កាត់ជំងឺរបេងដែលរដ្ឋាភិបាលជប៉ុនបានអនុវត្តន៍កន្លងមកដែរ។ ខ្ញុំសង្ឃឹមថា គម្រោងថ្ងៃនេះនឹងរួមចំណែកយ៉ាងធំចំពោះការទប់ស្កាត់ការរីករាលដាលនៃជំងឺរបេងផងដែរ។

រដ្ឋាភិបាលជប៉ុន គឺជាប្រទេសផ្តល់ជំនួយលំដាប់កំពូល ដែលបាននិងកំពុងផ្តល់ជំនួយដើម្បីស្តារនិងអភិវឌ្ឍន៍កម្ពុជាទៅលើវិស័យជាច្រើន យ៉ាងទូលំទូលាយ ចាប់តាំងពីឆ្នាំ១៩៩២មក។ ចំពោះវិស័យសុខាភិបាលនេះដែរ រដ្ឋាភិបាលជប៉ុនបាននិងកំពុងរួមចំណែកក្នុងការធ្វើឲ្យប្រសើរឡើងនូវវិស័យវិជ្ជសាស្ត្រសុខាភិបាលតាមរយៈការបំពាក់សម្ភារៈបរិក្ខាពេទ្យរួមទាំងមជ្ឈមណ្ឌលជំងឺរបេងជាតិ និង ការបណ្តុះបណ្តាលធនធានមនុស្សជាដើម។

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសផ្តល់ជំនួយរួមទាំងប្រទេស ជប៉ុនផងដែរនោះ យើងសង្កេតឃើញថាប៉ុន្មានឆ្នាំចុងក្រោយនេះ អត្រានៃការឆ្លងរាលដាលនៃជំងឺរបេង មានភាពល្អប្រសើរយ៉ាងខ្លាំង។ តែទោះជាយ៉ាងណា កម្ពុជានៅតែជាប្រទេសដែលកំពុងប្រឈមនឹងជំងឺរបេងកំរិតខ្ពស់នៅឡើយ ដូច្នេះទាមទារឲ្យមានការបន្តការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការកាត់បន្ថយអត្រានៃការឆ្លងជំងឺនេះ។

ខ្ញុំបានដឹងថា ការងារដែលសមាគមកំចាត់រោគរបេងជប៉ុន នឹងអនុវត្តន៍នៅស្រុកប្រតិបត្តិពារាំងក្នុងខេត្តព្រៃវែងនោះគឺ សមាគមមានគម្រោងពង្រឹងសមត្ថភាពការធ្វើរោគវិនិច្ឆ័យជំងឺរបេង ដើម្បីជំរុញបន្ថែមទៀតនូវការគាំទ្រទប់ស្កាត់ជំងឺរបេង។ តាមរយៈការអនុវត្តន៍គម្រោងនេះ ខ្ញុំសង្ឃឹមថាការពិនិត្យរកអ្នកឆ្លងជំងឺរបេងនឹងត្រូវបានរកឃើញក្នុងរយៈពេលយ៉ាងខ្លី ហើយព្យាបាលទាន់ពេលវេលា ឈានទៅដល់ការកាត់បន្ថយបាននូវការរីករាលដាលនៃការឆ្លងជំងឺរបេងនៅក្នុងតំបន់នោះ។

ជាចុងបញ្ចប់ ដោយជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន គឺជា ជំនួយដែលត្រូវបានផ្តល់ជូនដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាននោះ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះ ហត្ថលេខានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅ ព្រមទាំងរួម ចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និង កម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!